# សេចក្តីថ្លែងការណ៍រួមរបស់

## ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលទទួលបន្ទុកសាលាក្តីខ្មែរក្រហម
## និង
## ឯកឧត្តម ឯកអគ្គរដ្ឋទូត ដេវីត សេហ្វ័រ អ្នកជំនាញការពិសេស របស់អគ្គលេខាធិការ អង្គការសហប្រជាជាតិទទួលបន្ទុកសាលាក្តីខ្មែរក្រហម

*រាជធានីភ្នំពេញ* ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦

ខណៈពេលដែលអង្គជំនុំជម្រះតុលាការកំពូល កំពុងតែ ដំណើរការសវនាការក្នុងដំណាក់កាលចុងក្រោយលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/១ ដែលត្រូវបានផ្សព្វផ្សាយតាមទូរទស្សន៍ជាតិកម្ពុជា (ទទក) ទូទាំងប្រទេសនោះ ក៏មានកិច្ចប្រជុំក្នុងន័យស្ថាបនាមួយពាក់ព័ន្ធនឹងការវិវត្តថ្មីៗ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) ប្រព្រឹត្តទៅកាលពីម្សិលមិញ នៅទីស្តីការគណៈរដ្ឋមន្ត្រីរវាងឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន និង ឯកឧត្តម ឯកអគ្គរដ្ឋទូត ដេវីត សេហ្វ័រ នៅក្នុងអំឡុងពេលនៃទស្សនកិច្ចជាប្រចាំចុងក្រោយបំផុតរបស់ ឯកឧត្តម នៅព្រះរាជាណាចក្រកម្ពុជា។

ភាគីទាំងពីរបានសំដែងនូវការគាំទ្រយ៉ាងពេញទំហឹងចំពោះកិច្ចការរបស់សាលាក្តី ព្រមទាំងបានកត់សម្គាល់ថាអង្គជំនុំជម្រះសាលាដំបូង កំពុងតែបន្តជំនុំជម្រះក្តីក្នុងសំណុំរឿង០០២/០២ ហើយតាមគម្រោងផែនការបញ្ចប់ ក៏រំពឹងទុកថាការជំនុំជម្រះក្តីលើសំណុំរឿងនេះ នឹងបញ្ចប់នៅត្រឹមត្រីមាសទី៤ ឆ្នាំ២០១៦ និង សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលលើសំណុំរឿង០០២/០១ នឹងចេញនៅពាក់កណ្តាលឆ្នាំនេះ និងបានកត់សម្គាល់ផងដែរថា សាលាក្តីបានបោះជំហានទៅមុខយ៉ាងច្រើនជំហាននៅក្នុងប៉ុន្មានខែថ្មីៗនេះពាក់ព័ន្ធនឹងនីតិវិធីនៃសំណុំរឿង០០៣និង០០៤។

ភាគីទាំងពីរ បានទទួលស្គាល់នូវការគាំទ្រហិរញ្ញវត្ថុជាបន្តពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាដល់ភាគីជាតិនៃ អ.វ.ត.ក ដែលមានជាសាច់ប្រាក់ស្មើនឹងចំនួនសរុប២២,៦លានដុល្លារអាមេរិក គិតចាប់តាំងពីឆ្នាំ២០០៦មក និងវិភាគទានជាសម្ភារៈ និង សេវាផ្សេងៗ ដែលគិតជាទឹកប្រាក់ដោយរាជរដ្ឋាភិបាលប្រហែលជាង១៣លានដុល្លារអាមេរិកថែមទៀត។ ភាគីទាំងពីរ ក៏បានកត់សម្គាល់ដោយកោតសរសើរផងដែរ ចំពោះការផ្តល់ថវិកាស្ម័គ្រចិត្តពីម្ចាស់ជំនួយអន្តរជាតិ និងជំនួយបន្ថែមទៀតពីអង្គការសហប្រជាជាតិ ដែលធ្វើឲ្យភាគីអន្តរជាតិ និង ភាគីជាតិនៃអ.វ.ត.ក. មានលទ្ធភាពបន្តប្រតិបត្តិការរបស់ខ្លួនដោយមានការគាំទ្រថវិកាពេញលេញជារៀងរាល់ឆ្នាំ។ ភាគីទាំងពីរក៏បានពិភាក្សារក

វិធីសាស្ត្រសម្រេចឲ្យបាននូវថវិការស្ម័គចិត្តសម្រាប់ឆ្នាំ២០១៦ និងបានអំពាវនាវឲ្យមានការវិភាគទានរបស់អន្តរជាតិឲ្យបានទាន់ពេលវេលាសម្រាប់ភាគីទាំងពីរគឺភាគីជាតិនិងភាគីអន្តរជាតិនៃសាលាក្តី ក្នុងនោះរួមមានបណ្តារដ្ឋាភិបាលអាស៊ានផងដែរ។

ជាថ្មីម្តងទៀត នៅសប្តាហ៍នេះ សាលសវនាការនៃ អ.វ.ត.ក. ត្រូវបានបំពេញទៅដោយអ្នកសង្កេតការណ៍ និង សាធារណជនមកពីទូទាំងប្រទេសដែលភាគច្រើននៃអ្នកចូលរួមទាំងនោះ គឺត្រូវបានរៀបចំចាត់ចែងនាំមកសាលាក្តីដោយផ្នែកកិច្ចការសាធារណៈ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីជិត ៤០០០នាក់ ក្នុងសំណុំរឿង០០២ ក៏បានចូលរួមផងដែរ ដែលត្រូវបានដឹកនាំមកដោយផ្នែកគាំពារជនរងគ្រោះតាមរយៈការគាំទ្រពីប្រទេសអាល្លឺម៉ង់ និង ពីមូលនិធិអង្គការសហប្រជាជាតិសម្រាប់បញ្ចប់អំពើហឹង្សាលើស្ត្រី (UN Trust Fund to End Violence against Women)។ ការចូលរួមរបស់សាធារណជនដ៏ច្រើនមិនដែលធ្លាប់មាន នៅក្នុងដំណើរការនីតិវិធីរបស់ អ.វ.ត.ក គឺជាសមទ្ធិផលពិសេសមួយ ក្នុងចំណោមសមទ្ធិផលពិសេសៗទាំងឡាយ ហើយក៏មានការគាំទ្រពីបណ្តាអង្គការក្រៅរដ្ឋាភិបាលខ្លះៗក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ។ ភាគីទាំងពីរ បានកត់សម្គាល់ថា រហូតមកទល់ពេលនេះ ប្រជាជនកម្ពុជាជាតិជិតកន្លះលាននាក់បានមកទស្សនាសាលាក្តី ឬ បានចូលរួមនៅក្នុងកម្មវិធីផ្សព្វផ្សាយនៅទូទាំងប្រទេស ដែលតួលេខនេះបង្ហាញអំពីសារៈសំខាន់ដ៏ពិសេស ដែលតភ្ជាប់គ្នារវាងប្រជាជនកម្ពុជាទៅនឹងកិច្ចការរបស់ អ.វ.ត.ក ព្រមទាំងផ្តល់នូវគំរូដ៏ល្អមួយសម្រាប់សាលាក្តីដទៃទៀត ដែលមានលក្ខណៈដូចគ្នានេះ។

សមិទ្ធផលទាំងអស់នេះ រួមមានការបំពេញអាណត្តិយុត្តិធម៌របស់ខ្លួន ការអនុវត្តកម្មវិធីផ្សព្វផ្សាយ និង ការផ្តល់ការគាំទ្រដល់ការចូលរួមរបស់ជនរងគ្រោះ ពិតជាបង្ហាញនូវគុណតម្លៃរបស់ អ.វ.ត.ក និង បម្រើដល់ការប្រឆាំងតបទៅនឹងការយល់ខុសទាំងឡាយ ដែលផ្សព្វផ្សាយជាមតិយោបល់មកលើសាលាក្តីម្តងម្កាលនោះ។

ភាគីទាំងពីរបានសម្តែងនូវការកោតសរសើរចំពោះបណ្តាប្រទេសជាង៣០ ដែលបានគាំទ្រផ្នែកហិរញ្ញវត្ថុដល់អ.វ.ត.ក ចាប់តាំងពីការបង្កើតដំបូង និងកោតសរសើរចំពោះការបន្តគាំទ្ររបស់ប្រព័ន្ធផ្សព្វផ្សាយកម្ពុជា និងអន្តរជាតិ ក្នុងការផ្សព្វផ្សាយនៅទូទាំងប្រទេស នូវរាល់កិច្ចការសំខាន់ៗរបស់សាលាក្តីក្នុងដំណើរការស្វែងរកយុត្តិធម៌សម្រាប់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅកម្ពុជាប្រមាណ៤០ឆ្នាំមុន។